ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍
និងព័ត៌មាន

# សេចក្ដីជូនព័ត៌មាន

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៣០ ក្រោមមូលបទ «រួមគ្នាជាដៃគូដើម្បីធ្វើការផ្លាស់ប្ដូរ រួមចំណែកជាមួយពិភពលោក» ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១៧ នៅទីក្រុងម៉ានីល សាធារណរដ្ឋហ្វីលីពីន តបតាមការអញ្ជើញរបស់ឯកឧត្ដម រ៉ូឌ្រីហ្គោ រ៉ូ ឌូតឺតេ ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន។

ឥស្សរៈជនអមដំណើរសម្ដេចតេជោ ហ៊ុន សែន រួមមានៈ

- ឯកឧត្ដម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ឯកឧត្ដម ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- ឯកឧត្ដម ប៉ាន់ សូរស័ក្ដិ រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម និង
  សមាជិករាជរដ្ឋាភិបាលកម្ពុជាដ៏ទៃទៀត។

ក្នុងក្របខ័ណ្ឌកិច្ចប្រជុំកំពូលអាស៊ានលើកទី៣០នេះ សម្ដេចតេជោក៏នឹងចូលរួមក្នុងជំនួបរវាងថ្នាក់ដឹកនាំអាស៊ានជាមួយតំណាងអន្តរសភាអាស៊ាន និងជំនួបរវាងថ្នាក់ដឹកនាំអាស៊ានជាមួយតំណាងយុវជនអាស៊ានផងដែរ។

ក្នុងពេលដែលអាស៊ានកំពុងប្រារព្ធខួបលើកទី៥០នៅឆ្នាំ២០១៧នេះ នៅក្នុងឱកាសកិច្ចប្រជុំកំពូលអាស៊ានលើកទី៣០ ថ្នាក់ដឹកនាំអាស៊ាននឹងធ្វើការពិភាក្សា និងផ្លាស់ប្ដូរទស្សនៈលើបញ្ហាជាសារវ័ន្តនានា ដែលអាស៊ាន និងពិភពលោកកំពុងប្រឈមមុខ ដើម្បីលើកដំកើងសន្តិភាព សន្តិសុខ និងវិបុលភាពថែមទៀតសម្រាប់តំបន់ និងពិភពលោក។ ការកំណត់អាទិភាពកិច្ចប្រឹងប្រែងរបស់អាស៊ានក្នុងដំណើរវិវត្តន៍និម្មាបនកម្មតំបន់ គឺជារបៀបវារៈរបស់អាស៊ាន ហើយក្នុងពេលជាមួយគ្នានេះដែរ ថ្នាក់ដឹកនាំអាស៊ាននឹងផ្ដោតការយកចិត្តទុកដាក់ផងដែរដល់បញ្ហាដែលទើបកើតមានឡើងមួយចំនួន ដូចជាស្ថានភាពសេដ្ឋកិច្ច និងនយោបាយពិភពលោក ដែលមានភាពមិនច្បាស់លាស់។

ក្នុងការត្រៀមរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៣០ នេះ ឯកឧត្ដមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន នឹងអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន កិច្ចប្រជុំលើកទី១៥របស់ក្រុមប្រឹក្សាសហគមន៍

អាសយដ្ឋានៈ លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

នយោបាយ-សន្តិសុខអាស៊ាន និងកិច្ចប្រជុំលើកទី៩របស់ក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ដែលនឹងប្រព្រឹត្តទៅនៅមុនកិច្ចប្រជុំកំពូលអាស៊ាន។

ក្នុងឋានៈជាអង្គការតំបន់ដ៏មានជោគជ័យ តួនាទី និងការទទួលខុសត្រូវរបស់អាស៊ានបានបន្តរីកធំឡើងជាលំដាប់ទៅលើបញ្ហាផ្សេងទៀតដែលស្ថិតនៅក្រៅតំបន់ផងដែរ។ សភាពការណ៍នៅមជ្ឈឹមបូព៌ា និងនៅឧបទ្វីបកូរ៉េ ក៏ដូចជានៅលើពិភពលោក រួមទាំងសុខភាពសេដ្ឋកិច្ចពិភពលោក គឺជាការព្រួយបារម្ភខ្លាំងបំផុតរបស់អាស៊ាន។

នៅចុងបញ្ចប់នៃកិច្ចប្រជុំកំពូលនេះ នឹងមានចេញផ្សាយសេចក្តីថ្លែងការណ៍របស់ប្រធានកិច្ចប្រជុំ ហើយឯកសារមួយចំនួនក៏រំពឹងថានឹងត្រូវបានចុះហត្ថលេខា/អនុម័ត និងកត់សំគាល់ផងដែរ។

ភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧